# រឿង បុរសម្នាក់ស្រលាញ់ប្រពន្ធគេ

មាននិទានមួយដំណាលថា : បុរសមានប្រពន្ធក្រមុំរូបឆោមល្អ មានបុរសម្នាក់ស្រលាញ់ប្រពន្ធបុរសនោះ តែងមកចាំឃ្លាំមើលនៅកំពង់ទឹកតែសព្វថ្ងៃ ។ នាងនោះយល់បុរសនោះចេះតែមកឃ្លាំមើលរកតែងូតទឹកពុំបានដូច្នោះ ក៏និយាយថា "ថៅអើយ ! ម្តេចមកចាំនៅនេះរកតែអញងូតទឹកពុំបាន" ។ ថៅនោះថា "ត្បិតអញស្រលាញ់នាងទើបអញមកចាំនាងនៅនេះ" ។ នាងនោះថា "អញមានប្តីហើយកុំថៅមកចាំអញធ្វើអ្វី ចូរទៅផ្ទះវិញទៅ អញនឹងងូតទឹក" ។ ថៅនោះថាអញស្រលាញ់នាងពេក នឹងដើរចេញពុំបានឡើយ លុះតែនាងដោយអញ ទើបអញដើរចេញពីនេះ បើនាងពុំដោយអញៗ ពុំដើរចេញពីទីនេះឡើយ, អញចាំនាងគ្រាតែបាន"។ នាងនោះគិតក្នុងចិត្តថា "អញនឹងធ្វើដូចម្តេចអែះ បើដូច្នេះអញដោយគាត់ទៅចុះ" ហើយនាងនោះក៏ដោយគាត់ទៅចុះ ។ លុះបានជាស្មន់អន្ទករហើយ នាងនោះថា "ថៅអើយ ! ណ្ហើយទៅលំនៅវិញចុះ" ។ ថៅនោះថា "នាងអើយកាលពុំទាន់បានខ្លួននាងម្តេចអញពុំទៅ ចំណង់បើឥឡូវនេះអញបាននាងស្មន់អន្ទករហើយ រកពីណាអញទៅ អញពុំទៅឡើយ" ។ មេនោះថា " កាលថៅពុំទាន់បានអញជាស្មន់អន្ទករនោះថៅដើរចេញពុំបាន ឥឡូវនេះអញដោយថៅហើយ តើថៅនៅចាំអញធ្វើអ្វីទៀត" ។ ថៅនោះថា "អញយកនាងជាភរិយា អញឲ្យបាន កុំនាងសន្ទិះឡើយ នាងនោះថា "អញមានប្តីហើយ អញខ្លាចប្តីអញណាស់" ។ ថៅនោះថា "នាងខ្លាចប្តីនាង នោះឯង ៗ ទេអញនឹងរកកលកុំឲ្យប្តីនាងដឹង នាងកុំខ្លាចឡើយ" ។ ទើបថៅនោះដើរចេញ ទៅឃើញខ្មោចស្រីមួយគេចោលនោះព្រៃ លុះដល់យប់ ថៅនោះយកខ្មោចនោះមកទុកមួយអន្លើជិតផ្ទះនោះ លុះប្តីដេកលក់ ទើបថៅនោះយកខ្មោចនោះទៅផ្តេកខាងប្តីមេនោះ ហើយនាំប្រពន្ធថៅនោះចុះអំពីផ្ទះស្រឡះចេញ ទើបវាយកភ្លើងដុតផ្ទះថៅនោះ ។ ប្តីដឹងក៏ក្រោកឡើងដាស់ខ្មោចដោយស្មានថាប្រពន្ធថា "នែ ! ក្រោកឡើងភ្លើងឆេះផ្ទះម្តេចក៏ដេកធ្វើព្រងើយ " ថៅប្តីនោះកើចដៃខ្មោចឡើង ខ្មោចនោះរឹងស្តូកនៅកន្ទេលលុះភ្លើងឆេះក្តៅនឹងនៅពុំបាន ថៅនោះលោតចុះពីផ្ទះទៅឈរទ្រហោយំថា " ឱប្រពន្ធអញអើយ ម៉្លេះហើយ ភ្លើងរោលស្លាប់ហោង ឱអ្នកស្រុកអើយ ! ជួយអញតិចរ៉" ។ ដោយថៅនោះជឿស្មោះថាជាប្រពន្ធឯងបានជាយំសោកក្រៃពេក ។ លុះព្រឹកឡើងបុរសនោះ ទៅរកមនុស្សដាក់ខ្មោចនោះ ហើយបុរសនោះរត់ខ្ចីប្រាក់គេលើកខ្មោច រួចហើយទើបថៅនោះ រណ្តាប់រទេះក្របីគោបរចេញទៅជួញ បានប្រាក់មកសងគេខ្លះនៅខ្លះនៅឡើយ ។ លុះបុរសនោះទៅជួញឯស្រុកដទៃទៀត បានជួបនឹងប្រពន្ធនោះឯង ហើយនិយាយថា "នាងនេះជាប្រពន្ធអញ ម្តេចថៅនាំពង្រត់ប្រពន្ធអញមក ?" ។ បុរសស្មន់អន្ទករនោះថា "ម្តេចថៅមកចំហូរអញ ថាអញនាំពង្រត់ប្រពន្ធថៅឯងមក ? ក្រែងប្រពន្ធថៅឯងភ្លើងឆេះទៅហើយឬ" ។ ម៉្លេះហើយថៅទាំង ២ ដណ្តើមគ្នានាំគ្នាទៅដល់ថៅក្រម ៗ ពិចារណាពុំបាន ទើបនាំសេចក្តីនោះឡើងក្រាបបង្គំទូលព្រះមហាក្សត្រដោយដំណើរទីទៃ ៗ ។ ថៅមួយទូលថា "ថៅនេះចំហូរប្រពន្ធខ្ញុំព្រះបាទអម្ចាស់ថាជាប្រពន្ធគាត់ ប្រពន្ធគាត់ភ្លើងឆេះទៅហើយ" ។ ឯបុរសជាប្តីថាទូលថា "ស្រីដែលភ្លើងឆេះនោះ មិនមែនប្រពន្ធខ្ញុំព្រះបាទអម្ចាស់ទេ នាងនេះទេតើជាប្រពន្ធខ្ញុំព្រះបាទអម្ចាស់សូមព្រះអង្គទ្រង់ព្រះពិចារណា" ។ ព្រះមហាក្សត្រទ្រង់ពិចារណាថា " សេចក្តីនេះ កម្រអ្នកឯណារកបាន លុះតែរកដោយកលប្រាជ្ញាទើបបាន ក៏ទ្រង់ឲ្យអាមាត្យម្នាក់ចូលក្នុង

ស្គរ ចាំស្តាប់សម្តីស្រីនឹងប្រុសនោះ ឲ្យប្តីនឹងប្រពន្ធនោះសែងស្គរទៅ លុះសែងស្គរទៅ មេនោះឥតថាអ្វីឡើយ រួចឲ្យបុរសស្មន់អន្ទកនិងមេនោះសែងវិញ ទើបមេនោះថា “ បើអញនៅនឹងប្តីអញ មិនពិបាកដូច្នេះទេ ” ។ បុរសស្មន់អន្ទករនោះថា “ កុំនិយាយខ្លាចគេឮ ” ។ មេនោះថាអញមិននិយាយឯណាបាន អញខ្លាចអ្វី បើធ្ងន់ស្មើរបាក់ស្មា ដូច្នេះថាឯងបារម្ភអ្វី បើចៅទើបតែសែងតែម្តង ឯអញពីរដងហើយ ធ្ងន់ស្មើរស្លាប់” ។ អាមាត្យនៅក្នុងស្គរស្តាប់ឮពាក្យមេនោះនិយាយដូច្នោះ ហើយក៏កត់ត្រាតាមពាក្យនោះ ។ លុះសែងបានដល់កំណត់ហើយចូលមក គេយកអាមាត្យនោះចេញពីក្នុងស្គរ ហើយអាមាត្យយកតម្រានោះមកសូត្រថ្វាយព្រះមហាក្សត្រ ទើបព្រះអង្គបង្គាប់ឲ្យប្តីឈ្នះ ហើយទ្រង់ឲ្យលក់អាប្រុសនឹងមេស្រីនោះ ដាច់សុរិល[1] ។ ព្រះមហាក្សត្រទ្រង់កាត់សេចក្តីនេះបានដោយប្រាជ្ញាទិព្វវិសេសហោង ។